**សកម្មភាព** ៖ **ល្បែងមេរោគប៉ុមៗ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

**វិទ្យាសាស្រ្ត**

បំណិនអនាម័យ (ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្រ្ត)** ប្រាប់ពីទម្លាប់ល្អទាំងឡាយ មុន និងក្រោយពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត ចូលបង្គន់អនាម័យ សម្អាតខ្លួនប្រាណ ។

**(សិក្សាសង្គម)** ការបង្ហាញពីរសកម្មភាពផ្សេងៗទៀតដែលបានបង្កើតជាស្នាដៃ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “បិសាចចម្លែកតូចៗ” ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសកេះ អំបោះធំ ក្រដាសស ខ្មៅដៃពណ៌ និងកាវស្អិត

**ការរៀបចំ** ៖ ទិញអំបោះធំ កាត់ប្រវែងស្មើគ្នាសម្រាប់ចងប៉ុមៗទាំងអស់គ្នា។ កាត់ក្រដាសកេះជារាងចតុកោណកែង និងធ្វើកាវស្អិត ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**មេរោគប៉ុមៗ**ជាមួយកូនៗទាំងអស់គ្នា។
2. ប្រាប់ក្មេងៗថា៖ មេរោគមានច្រើនប្រភេទណាស់ ហើយមានរូបរាងខុសៗគ្នា។
3. កូនគួរតែទម្លាប់អនាម័យលាងដៃជាមួយសាប៊ូ និងទឹកឱ្យបានស្អាត។
4. ប្រាប់ក្មេងៗ៖ កូនៗនឹងបង្កើតមេរោគប៉ុមៗម្នាក់មួយជាមយយអ្នកគ្រូ ។

5. បង្ហាញពីរបៀបធ្វើមេរោគប៉ុមៗទៅកាន់ក្មេងៗទាំងអស់
    - កាត់ខ្សែអំបោះប្រវែងដែលអ្នកគិតថាអាចចងប៉ុមៗបាន
    - បន្ទាប់មកដាក់វានៅលើក្រដាសកេះដែលមានរាងចតុកោណនោះតាមបណ្ដោយក្រដាសកេះ
    - បន្ទាប់មកយកខ្សែអំបោះធំ រុំជុំវិញក្រដាសកេះដែលរុំពីលើខ្សែដែលកាត់នោះ។ រុំប៉ុន្មានជុំក៏បានដែរ ទៅតាមការពេញចិត្តរបស់អ្នក។




    - បន្ទាប់មក ចងវាឱ្យបានជាប់ល្អ
    - ហើយកាត់អំបោះដែលអ្នករុំជុំវិញហ្នឹង ហើយរុះវាឱ្យចេញជារាងមូលដូចនៅក្នុងរូប
6. គូររូបភ្នែក និងច្រមុះឱ្យបានស្អាត បន្ទាប់មក បិទវានៅលើប៉ុមៗ
7. ចែងសម្ភារទាំងអស់ទៅក្មេង
8. ជួយក្មេងប្រសិនបើពួកគេត្រូវការជំនួយគឺជាការស្រេច។

